World Health Organization Thailand

TICA

# Know COVID

# รู้ทันโควิด



สาระคัดสรรเพื่อรู้ทันโควิด เราจะผ่านวิกฤตครั้งนี้ไปด้วยกัน

PRACTICAL KNOWLEDGE TO KEEP UP WITH COVID WE WILL GET THROUGH THIS CRISIS TOGETHER

# ១២

# ចំណុចនៃការយល់ឃើញខុសទៅលើវីរុស
# កូវីដ-១៩



*In collaboration with*
*The Royal Embassy of Cambodia in Thailand*

## ១ វីរុសកូវីដ-១៩អាចចម្លងតាមរយៈទំនិញដែលផលិតនៅក្នុងប្រទេសដែលកំពុងមានការរាតត្បាតមែនដែរឬទេ ?




ទោះបីវីរុសកូវីដ-១៩ អាចស្ថិតនៅលើស្បែកបានច្រើនម៉ោង ប៉ុន្តែអាស្រ័យដោយកត្តាបរិយាកាសជុំវិញ រយៈពេលការផ្លាស់ទី និងសីតុណ្ហភាពផ្សេងៗក្នុងពេលធ្វើដំណើរទៅចម្លង ក៏ជាកត្តាដែលធ្វើអោយមេរោគមិនអាចរស់បានយូរ។ ករណីស្បែកមានភាពកខ្វក់ឬអ្នកមានអារម្មណ៍ថាបានប៉ះពាល់របស់ដែលអាចមានផ្ទុកវីរុសកូវីដសូមលាងសម្អាតដៃដោយសាប៊ូ ឬធ្វើការសម្អាតដៃដោយសារធាតុដែលអាចសម្លាប់មេរោគបាន។

## ២ វីរុសកូវីដ-១៩ អាចចម្លងតាមរយៈមូសខាំបានដែរឬទេ

នៅមិនទាន់មានព័ត៌មានដែលបង្ហាញថាវីរុសកូរ៉ូណាប្រភេទថ្មីនេះអាចចម្លងតាមរយៈការចម្លងដោយមូសខាំ។ វីរុសនេះអាចចម្លងតាមរយៈការក្អក កន្ទាស់ ឬតាមរយៈទឹកមាត់របស់អ្នកជម្ងឺ។



## ៣ តើអាចទុកចិត្តយ៉ាងម៉េចទៅថាសំលៀកបំពាក់មិនបានជាប់វីរុសកូវីដ-១៩




ក្រៅពីត្រូវងូតទឹកសម្អាតខ្លួនជារៀងរាល់ថ្ងៃហើយ ការបោកសម្លៀកបំពាក់ដោយសាប៊ូសម្លាប់មេរោគ លាយនឹងទឹកដែលមានកម្តៅពី ៦០-៩០អង្សា ឬធ្វើការលាយជាមួយទឹកអូសាវ៉ែលរួចហាល សម្លៀកបំពាក់អោយបានស្ងួតល្អ។

## ៤ តើអាចពិសារស្រដើម្បីជួយការពារវីរុសកូវីដ-១៩ បានដែរឬទេ ?



ការពិសារគ្រឿងស្រវឹងដូចជា៖ ស្រាបៀរ ស្រាស ស្រាថ្នាំ ស្រាអ្វីក៏ដោយ វាមិនបានជួយការពារការឆ្លងវីរុសកូវីដទេ។ ផ្ទុយទៅវិញគួរតែធ្វើការការពារដោយការលាងសម្អាតដៃអោយបានញឹកញាប់ ពាក់ម៉ាស់ ជៀសវាងការនៅក្បែរអ្នកដែលមានអាការៈក្តៅខ្លួននិងក្អក។

## ៥ ពិតដែរឬទេដែលវីរុសកូវីដ-១៩ អាចឆ្លងបានតែនៅតំបន់ត្រជាក់ តែមិនអាឆ្លងនៅតំបន់ក្ដៅហើយសើម ?




វីរុសកូវីដ-១៩ អាចចម្លងបានៅគ្រប់តំបន់និង គ្រប់រដូវកាល មិនថាអ្នកនៅទីណា អាកាសធាតុបែបណា ដូច្នេះតម្រូវអោយយើងត្រូវអនុវត្តន៍តាមសេចក្ដីណែនាំ ដោយធ្វើការលាងដៃអោយបានញឹកញាប់ ខ្ទប់មាត់និង ច្រមុះពេលក្អកឬកណ្ដាស់ ឬប្រើប្រាស់ម៉ាស់ដើម្បីការពារ។

## ៦ គ្រឿងវាស់សីតុណ្ហាភាពអាចបញ្ជាក់ថាអ្នកមានផ្ទុកវីរុសកូវីដ-១៩ បាន ១០០%ដែរឬទេ ?




វីរុសអាចប្រើពេល ១-១៤ថ្ងៃក្នុងការធ្វើអោយអ្នកផ្ទុកមេរោគនេះឈឺនិងក្ដៅខ្លួន ដូច្នេះភ្លាមៗមិនអាចបញ្ជាក់ថាអ្នកណាមានផ្ទុកមេរោគនេះ។

## ៧ យកអំពូលភ្លើងយូវី ( UV ) មកសំលាប់ជំងឺកូវីដ ១៩ នៅលើរាងកាយបានដែរឬទេ




មិនគួរប្រើអំពូលភ្លើងយូវី (UV)
មកសំលាប់មេរោគលើដៃ
ឬផ្នែកផ្សេងៗនៃរាងកាយនោះទេ
ព្រោះកាំរស្មីយូវី (UV)
ធ្វើអោយស្បែកជាំបាន។




## ៨ តើការបាញ់អាល់កុលឬក្លរីនលើរាងកាយរបស់មនុស្សម្នាក់ អាចសម្លាប់វីរុសកូវីដ-១៩ នៅក្នុងរាងកាយបានទេ ?




មិនត្រឹមតែមិនអាចសម្លាប់មេរោគដែលចូលក្នុងរាងកាយបាន ថែមទាំងអាចបំផ្លាញសម្លៀកបំពាក់ និងសរីរាង្គផ្សេងៗ ដូចជា ភ្នែក មាត់ជាដើម។

## ៩ ការបរិភោគខ្ទឹមអាចការពារការឆ្លងជំងឺកូវីដ-១៩ បានដែរឬទេ?




ទោះបីវាមានគុណសម្បត្តិមេរោគខ្លះៗក៏ដោយ ក៏ប៉ុន្តែមិនមានផស្តុតាងណាមួយ
នៅបច្ចុប្បន្ននេះបានបញ្ជាក់ថាអាចការពារការឆ្លងវីរុសកូវីង-១៩ បានទេ។

## ១០ វ៉ាក់សាំងការពារជម្ងឺរលាកសួតអាចការពារយើងពីជម្ងឺកូវីដ-១៩ បានទេ?




វីរុសនេះជាវីរុសថ្មី
និងប្លែកពីពពួកវីរុសប្រភេទ
ដើមណាស់ ដែលត្រូវការវ៉ាក់សាំង
ពិសេសដែលក្រុមស្រាវជ្រាវកំពុង
អភិវឌ្ឍន៍ដោយមានការគាំទ្រពីអង្គការ
សុខភាពពិភពលោក។

# ១១

# ការលាងច្រមុះជាប្រចាំជាមួយទឹកអំបិលអាចការពារការឆ្លងជម្ងឺកូវីដ-១៩ បានដែរឬទេ?




ភស្តុតាងបានបង្ហាញថាការលាងច្រមុះរបស់អ្នកជាមួយទឹកអំបិលនឹងធ្វើឲ្យយើងឆាប់ជាសះស្បើយពីជំងឺផ្ដាសាយធម្មតា។ ប៉ុន្តែមិនអាចជួយការពារការឆ្លងមេរោគផ្លូវដង្ហើមឬជំងឺកូវីដ-១៩ បានទេ។

# ១២ តើមានថ្នាំបង្ការនិងស្រមាប់ព្យាបាលជំងឺកូវីដ-១៩ បានដែរឬទេ?

នាពេលបច្ចុប្បន្ននេះមិនមានវិធីបង្ការ និងព្យាបាលទេ ជាពិសេសចំពោះអ្នកឆ្លង គួរតែទទួលបានការរក្សាព្យាបាលដែលត្រឹមត្រូវសមស្រប ដើម្បីកាត់បន្ថយអាការៈ និងព្យាបាលតាមអាការៈ។ អង្គការសុខភាពពិភពលោកកំពុងគាំទ្រការស្រាវជ្រាវជាមួយភ្នាក់ងារដៃគូរ និង សិក្សាយ៉ាងសកម្មក្នុងការព្យាបាលជម្ងឺនេះ។

